## ត្រាសម្គាល់ជំនាញទ្វេភាសា

# រដ្ឋមេន (MAINE)




ជាទឹកដីដែលឥឡូវនេះគេហៅថា រដ្ឋ Maine ជាទីកន្លែងនៃបេតិកភណ្ឌភាសាដែលមានភាពស៊ីជម្រៅសម្បូរបែប និងយូរអង្វែង។ សមត្ថភាពក្នុងការនិយាយបានច្រើនភាសាលើសពីមួយភាសាឡើងទៅ មិនមែនគ្រាន់តែជាចំណុចខ្លាំងផ្នែកអប់រំប៉ុណ្ណោះទេ—ប៉ុន្តែវាថែមទាំងឆ្លុះបញ្ចាំងពីការតភ្ជាប់ដ៏រឹងមាំទៅកាន់វប្បធម៌ អត្តសញ្ញាណ និងការផ្សារភ្ជាប់ទៅនឹងសហគមន៍ផងដែរ។



**FRED RAVAN**
**ជាគ្រូបង្រៀនភាសាអេស្ប៉ាញ និងជាប្រធានអ្នកអប់រំពហុភាសា រដ្ឋ MAINE (EMME)**

"ត្រាសម្គាល់ជំនាញទ្វេភាសាគឺជា**ឧបករណ៍មួយប្រកបដោយសមភាពសម្រាប់សិស្សគ្រប់រូប** ពីព្រោះវាបានផ្តល់ឱកាសដល់សិស្សឱ្យបានចូលសិក្សាភាសាដែលពួកគេមិនធ្លាប់បានទទួលឱកាសនេះពីមុនមក។
តាមពិត យើងកំពុងស្វែងរកមធ្យោបាយដើម្បីឱ្យ**សិស្សគ្រប់កម្រិតថ្នាក់**បានធ្វើតេស្តសាកល្បង ដើម្បីយើងអាចធ្វើការតាមដានពីវឌ្ឍនភាពលទ្ធផលសិក្សាភាសារបស់ពួកគេបាន ពីមួយឆ្នាំទៅមួយឆ្នាំ។"



សិស្សវិទ្យាល័យ Bangor ដែលបានទទួលពានរង្វាន់ក្នុងឆ្នាំសិក្សា 2024-2025

Khmer

# អំពីត្រាសម្គាល់ជំនាញទ្វេភាសា

នេះគឺជាការទទួលស្គាល់ជាផ្លូវការដែលផ្តល់ឱ្យដោយរដ្ឋ ហើយត្រូវបានដាក់បញ្ចូលនៅក្នុងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ និងព្រឹត្តិបត្រពិន្ទុរបស់សិស្ស ដើម្បីបង្ហាញពីជំនាញពីរភាសា ឬច្រើនជាងពីរភាសាឡើងទៅ។
សិស្សគ្រប់រូបអាចប្រើប្រាស់ត្រាសម្គាល់ជំនាញទ្វេភាសានេះបាន សូម្បីតែសិស្សដែលរៀននិយាយភាសាដំបូងមិនមែនជាភាសាអង់គ្លេសនៅផ្ទះក៏ដោយ។



**BOBIN PARK និស្សិតនៅមហាវិទ្យាល័យ BOWDOIN**

"ការនិយាយបានច្រើនភាសាធ្វើឱ្យខ្ញុំអាចផ្សារភ្ជាប់ទៅនឹងវប្បធម៌របស់ខ្ញុំកាន់តែល្អប្រសើរ និងអាចមើលឃើញពីទស្សនៈលើពិភពលោកកាន់តែទូលំទូលាយឡើង។"



**PAULINA SARGENT គ្រូបង្រៀនភាសាអេស្ប៉ាញ**

"ត្រាសម្គាល់ជំនាញទ្វេភាសានេះពិតជាបានផ្តល់ការទទួលស្គាល់ដ៏ស័ក្តិសមបំផុតចំពោះការខិតខំប្រឹងប្រែងសិក្សារបស់សិស្សខ្ញុំ។ **នៅពេលយើងមើលផែនទីផ្ទាំងព័ត៌មានរបស់ក្រសួងអប់រំ (DOE)** យើងពិតជាមានមោទនភាពខ្លាំងណាស់ដែលយើងបានឃើញសាលាដ៏តូចរបស់យើងមានវត្តមាននៅទីនោះដែរ។»

# ដើម្បីចាប់ផ្តើមចូលរួម

សូមបំពេញលក្ខខណ្ឌខាងក្រោម ដើម្បីទទួលបានត្រាសម្គាល់ជំនាញទ្វេភាសានៅពេលបញ្ចប់ការសិក្សា។

- ជំនាញភាសាអង់គ្លេស
  *(ការបញ្ចប់ការសិក្សាថ្នាក់វិទ្យាល័យ)*
- ជំនាញភាសាទីពីរ
  *(ការវាយតម្លៃភាសាពិភពលោក)*

សូមដាក់ពាក្យសុំសិក្សារបស់អ្នកទៅសាលារៀនឱ្យបានត្រឹមថ្ងៃទី 30 ខែកក្កដា។ គ្មានការបង់ថ្លៃសេវាបន្ថែមក្នុងការដាក់ពាក្យសុំសិក្សាទេ បន្ទាប់ពីអ្នកបានបង់ប្រាក់ និងប្រឡងភាសារួចរាល់ហើយ។

ត្រាសម្គាល់ជំនាញទ្វេភាសានេះទទួលស្គាល់ទៅលើជំនាញភាសារបស់សិស្សថាជាទ្រព្យដ៏មានតម្លៃ បញ្ជាក់ពីបេតិកភណ្ឌវប្បធម៌របស់ពួកគេ និងបញ្ជាក់ពីការត្រៀមខ្លួនរបស់ពួកគេសម្រាប់ការចូលរៀននៅមហាវិទ្យាល័យ អាជីព និងឱកាសនានាជាសកល។

សូមសាកសួរអ្នកសម្របសម្រួលផ្នែកត្រាសម្គាល់ជំនាញទ្វេភាសា នៅវិទ្យាល័យរបស់អ្នក ដើម្បីទទួលបានព័ត៌មានបន្ថែម។ សូមប្រញាប់រួសរាន់រៀបចំផែនការសិក្សារបស់អ្នកឱ្យបានឆាប់រហ័ស!

# អត្ថប្រយោជន៍របស់ត្រាសម្គាល់ជំនាញទ្វេភាសា

សិស្សទទួលបានអត្ថប្រយោជន៍ប្រកបដោយអត្ថន័យ និងអាចប្រើប្រាស់បានក្នុងជីវភាពប្រចាំថ្ងៃជាក់ស្តែងពីការទទួលបានត្រាសម្គាល់ជំនាញទ្វេភាសានេះ មិនត្រឹមតែជាជោគជ័យក្នុងការប្រឡងប៉ុណ្ណោះទេ។

## 1. មហាវិទ្យាល័យ



### ក្រេឌីតមហាវិទ្យាល័យ រដ្ឋ MAINE

កត្តាជំរុញលើកទឹកចិត្តដ៏ធំបំផុតដល់សិស្សក្នុងការទទួលយកត្រាសម្គាល់ជំនាញទ្វេភាសានេះ គឺក្រេឌីតសម្រាប់មហាវិទ្យាល័យ។ នៅរដ្ឋ Maine មានមហាវិទ្យាល័យចំនួន 6 ដែលបានផ្តល់ក្រេឌីតសម្រាប់មហាវិទ្យាល័យដល់សិស្សដែលបានទទួលត្រាសម្គាល់ជំនាញទ្វេភាសានេះ (គិតត្រឹមខែសីហា ឆ្នាំ 2025)។

**សាកលវិទ្យាល័យ រដ្ឋ Maine នៅ Farmington**
6 ក្រេឌីត

**សាកលវិទ្យាល័យ រដ្ឋ Maine នៅ Orono**
6 ក្រេឌីត

**សាកលវិទ្យាល័យ រដ្ឋ Maine នៅ Machias**
6 ក្រេឌីត

**សាកលវិទ្យាល័យ ភាគខាងត្បូង រដ្ឋ Maine**
8 ក្រេឌីត

**មហាវិទ្យាល័យសហគមន៍ ភាគខាងត្បូង រដ្ឋ Maine**
8 ក្រេឌីត

**សាកលវិទ្យាល័យ Husson**
6 ក្រេឌីត

** យើងសូមណែនាំឱ្យអ្នកសាកសួរទៅមហាវិទ្យាល័យរបស់អ្នក ថាតើពួកគេតម្រូវឱ្យមានការការប្រឡងជាក់លាក់ណាមួយឬអត់ដើម្បីពួកអាចទទួលយកក្រេឌីតនេះបាន។



**82.6% នៃសិស្សដែលទទួលបានត្រាសម្គាល់ជំនាញទ្វេភាសាពីរដ្ឋ MAINE បានចុះឈ្មោះបន្តការសិក្សានៅមហាវិទ្យាល័យ។**

(គិតត្រឹមខែសីហា ឆ្នាំ2025)។

### ការទទួលនិស្សិតឱ្យចូលសិក្សានៅមហាវិទ្យាល័យ

ក្រៅពីការផ្តល់ក្រេឌីតសម្រាប់មហាវិទ្យាល័យ ត្រាសម្គាល់ជំនាញទ្វេភាសានេះគឺជារង្វាន់មួយផងដែរ។ នៅពេលដែលការទទួលនិស្សិតឱ្យចូលសិក្សានៅមហាវិទ្យាល័យកាន់តែមានការប្រកួតប្រជែងខ្លាំង ត្រាសម្គាល់ជំនាញទ្វេភាសានេះត្រូវបានចាត់ទុកថាជាមូលបត្រសម្រាប់សិស្សដែលសម្រេចបានជោគជ័យខ្ពស់បំផុតដោយការិយាល័យជ្រើសរើសនិស្សិតឱ្យចូលសិក្សានៅមហាវិទ្យាល័យ។



### សាកលវិទ្យាល័យ រដ្ឋ MAINE នៅ FARMINGTON

**LISA ELLLRICH នាយកផ្នែកទទួលនិស្សិតឱ្យចូលសិក្សា**

**បេក្ខជនដាក់ពាក្យសុំសិក្សាដែលមានត្រាសម្គាល់ជំនាញទ្វេភាសានេះត្រូវបានទទួលស្គាល់ថាជា**សិស្សឧស្សាហ៍ព្យាយាមសិក្សាដែលអាចនឹងចាប់យកឱកាសសិក្សាបានល្អ និងសម្រេចបាននូវឧត្តមភាពពិសេសក្នុងជំនាញភាសា។ ត្រាសម្គាល់ជំនាញទ្វេភាសានេះក៏**បង្ហាញពីសមត្ថភាព នឹងការខិតខំប្រឹងប្រែងសិក្សារបស់សិស្សមួយផ្នែកទៀតផងដែរ ដែលយើងមិនអាចមើលឃើញបាន**តាមរយៈការមើលព្រឹត្តិបត្រពិន្ទុមួយភ្លែតបានទេ។

**សាកលវិទ្យាល័យ រដ្ឋ Maine នៅ Farmington បានប្រារព្ធពិធីអបអរសាទរដល់សិស្សដែលទទួលបានត្រាសម្គាល់ជំនាញទ្វេភាសានេះ** នៅក្នុងពិធីបុណ្យជាច្រើនជារៀងរាល់ឆ្នាំ។ យើងផ្តល់ឱកាសដល់ពួកគេឱ្យបានចូលរួមចែករំលែកបេតិកភណ្ឌភាសារបស់ពួកគេជាមួយសហគមន៍**នៅក្នុងបរិវេណសាកលវិទ្យាល័យ** និងជួយគាំទ្រដល់ពួកគេ 100% គ្រប់ជំហានទាំងអស់!

ការសិក្សាភាសាបើកចំហឱកាសឆ្ពោះទៅរកការផ្សារភ្ជាប់ទំនាក់ទំនងគ្នា និងការផ្លាស់ប្តូរវប្បធម៌គ្នាទៅវិញទៅមក — ទាំងនៅលើពិភពលោក និងនៅទីនេះនៅក្នុងរដ្ឋ Maine — ដោយការតភ្ជាប់សហគមន៍ទាំងអស់ និងលើកកម្ពស់កិច្ចសហការនៅទូទាំងទ្វីប។

## 2. ការងារ

និយោជកកាន់តែច្រើនកំពុងស្វែងរកបេក្ខជនរកការងារធ្វើដែលអាចនិយាយបានពីរភាសា ដើម្បីពង្រីកអតិថិជនសក្តានុពលរបស់ពួកគេបន្ថែម។ សិស្សដែលអាចនិយាយបានពីរភាសាផ្តល់អត្ថប្រយោជន៍ជាច្រើនដល់កន្លែងធ្វើការ ជាពិសេសនៅក្នុងកន្លែងការងារដែលផ្តល់តម្លៃដល់ការទំនាក់ទំនងជាមួយក្រុមមនុស្សចម្រុះគ្នា។

### ការិយាល័យធនធានមនុស្ស រដ្ឋ MAINE

ការិយាល័យធនធានមនុស្ស រដ្ឋ Maine ទទួលយកត្រាសម្គាល់ជំនាញទ្វេភាសានេះជាវិធានសមត្ថភាពនៃជំនាញភាសា។ និយោជិតក៏អាចដាក់ពាក្យស្នើសុំប្រាក់កម្រៃពហុភាសាបន្ថែមដើម្បីទទួលបានប្រាក់ឈ្នួលសម្រាប់ការនិយាយភាសាផ្សេងទៀតនៅកន្លែងធ្វើការបានដែរ។



**AMELIA LYONS RUKEMA**
**នាយកប្រតិបត្តិ (CEO)**

### សុខភាពចល័តរបស់រដ្ឋ MAINE

“ក្នុងនាមជានិយោជកដែលកំពុងស្វែងរកបេក្ខជនដែលចេះពីរភាសា អ្នកមានត្រាសម្គាល់ជំនាញទ្វេភាសា គឺជាអ្នកសង្គ្រោះជីវិត! វាផ្តល់នូវមធ្យោបាយងាយស្រួលក្នុងការវាយតម្លៃជំនាញភាសានៅកម្រិតដែលយើងត្រូវការ ដោយបានជួយសន្សំសំចៃទាំងពេលវេលា និងថវិកាដល់យើង”។

សិស្សអាចមើលត្រាសម្គាល់ជំនាញទ្វេភាសានេះ នៅលើប្រវត្តិរូបសង្ខេប ពាក្យសុំចូលសិក្សានៅមហាវិទ្យាល័យ និងឯកសារការងារ ដើម្បីបង្ហាញពីសមត្ថភាពពហុភាសារបស់ពួកគេ និងបង្ហាញពីភាពលេចធ្លោនៅក្នុងពិភពដែលមានការប្រកួតប្រជែងខ្ពស់។